FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ

ឆ្នាំទី ១ លេខ ០៧ ខែធ្នូ ឆ្នាំ២០០២

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute



# ពូជស្រូវក្រអូប "សែនពិដោរ"

**ពូជ** "សែនពិដោរ" ជាពូជស្រូវក្រអូប ដែលបានធ្វើការបញ្ចេញ និងផ្សព្វផ្សាយជូនកសិករប្រើប្រាស់ដោយ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាដើមឆ្នាំ ២០០២។ បច្ចុប្បន្ន ពូជស្រូវសែនពិដោរ បាននឹងកំពុងរីកសាយភាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយពូជស្រូវនេះផ្តល់នូវទិន្នផលខ្ពស់ មានក្លិនក្រអូប គុណភាពអង្ករល្អមានភាពថ្លាវែងរលូន និងបាយទន់ឆ្ងាញ់ពិសារទៀតផង។ ជាពិសេសទៅទៀត ជាពូជដែលមានប្រភេទអង្ករមានតម្លៃខ្ពស់នៅលើទីផ្សារជាតិ និងអន្តរជាតិ។

## លក្ខណៈពិសេសៗរបស់ពូជស្រូវ សែនពិដោរ

**ពូជ**សែនពិដោរ ជាពូជស្រូវស្រាលមិនប្រកាន់រដូវ ដូចនេះពូជនេះអាចចេញផ្កាបានគ្រប់ពេលវេលា ដរាបណាល័ក្ខខណ្ឌដាំដុះអំណោយផល។ អាស្រ័យដោយហេតុផលខាងលើនេះ ទើបពូជសែនពិដោរ អាចដាំដុះនៅដើមរដូវវស្សា (ដំណាំទីមួយនៃរដូវ ឬស្រូវដើមរដូវ) ក្នុងរដូវវស្សា (ដំណាំទីពីរនៃរដូវ) ចុងរដូវវស្សា ស្រូវប្រេដញទឹក (ដំណាំចន្លោះរដូវវស្សា និងរដូវប្រាំង) និងល័ក្ខខ័ណ្ឌប្រាំងស្រោចស្រព។ ពូជស្រូវសែនពិដោរ មានអាយុកាលចាប់ពីថ្ងៃសាបរហូតដល់ថ្ងៃប្រមូលផលពី ១១០-១២០ ថ្ងៃ។ កម្ពស់ដើមប្រែប្រួលពី ៩៥-១១០ ស.ម និងចំនួន ដើមបែកគុម្ពផ្តល់ផលពី ៥-២០ ដើមក្នុងមួយគុម្ព ។ ចំនួនគ្រាប់ក្នុងមួយកួរមានចាប់ពី ១១០-១៧០ គ្រាប់ និងមានប្រវែងកួរពី ២០-៣០ ស.ម។ ពូជស្រូវសែនពិដោរ មិនធន់ទៅនឹងមមាចត្នោតទេ និងអាចផ្តល់ផលពី ៣,៥ ទៅ ៥,៥ តោនក្នុង ១ ហិកតា។

## វិធីសាស្ត្រដាំដុះ

**សម្រាប់**ស្រូវសន្ទូង បរិមាណគ្រាប់ពូជដែលចាំបាច់គឺពី ៣០-៤០ គីឡូក្រាម ក្នុង ១ ហិកតា ប៉ុន្តែក្នុងករណីដែលគ្រាប់ពូជសុទ្ធ និងមានសុខភាពល្អ បរិមាណគ្រាប់ពូជ ដែលត្រូវការក្នុងមួយហិកតាគឺពី ១៥-២០ គីឡូក្រាម។ ដើម្បីឲ្យសំណាបដុះលូតលាស់ធំធាត់ល្អ គេត្រូវសាបគ្រាប់ពូជមួយគីឡូក្រាមលើផ្ទៃដីថ្នាល ១០ ម៉ែត្រការ៉េ។ ទីសំណាបត្រូវធ្វើនៅជិតប្រភពទឹក តែត្រូវឆ្ងាយពីម្លប់ព្រៃ ឬកន្លែងមាន ភ្លើងអគ្គីសនី ដើម្បីចៀសវាងការបំផ្លាញពីសត្វល្អិតចង្រៃ។ ជាការល្អគួរស្ទូងសំណាបដែលមានអាយុ ១៨-២២ ថ្ងៃ ហើយក្នុងមួយគុម្ពចំនួន ២-៣ ដើម។ សម្រាប់ស្រូវពង្រោះ បរិមាណគ្រាប់ពូជដែលចាំបាច់គឺ ៦០ គីឡូក្រាមក្នុង ១ ហិកតា។ គួររៀបចំដីឲ្យបានល្អ និងរាបស្មើមុនស្ទូង ឬព្រោះ។ ការភ្ជួររាស់ គួរតែធ្វើឲ្យបាន ២-៣ សារជាការល្អប្រសើរ។ ប្រសិនបើស្រែអាចបញ្ចេញបញ្ចូលទឹកបាន បន្ទាប់ពីស្ទូង ឬព្រោះបាន ២០ ថ្ងៃ អាចបញ្ចេញទឹកឲ្យអស់ពីក្នុងស្រែ ២-៤ ថ្ងៃ រួចបញ្ចូលទឹកថ្មីវិញ។ ធ្វើរបៀបនេះគឺដើម្បីធ្វើឲ្យស្រូវកាន់តែបែកគុម្ពល្អ។





## ការប្រើប្រាស់ជី

**ការ**ប្រើប្រាស់ជីសមស្របតាមកម្រិតណែនាំ នឹងមិនបណ្ដាលឲ្យមានការថយគុណភាពគ្រាប់ស្រូវឡើយ។ គួរដាក់ជី ២-៣ ដង ក្នុងមួយវដ្ដជីវិតរបស់ស្រូវដោយៈ

-បាចលើកទី១៖ ទ្រាប់បាតមុនពេលស្ទូងប្រើជីធម្មជាតិពី ៥ តោន (២០ រទេះ) ក្នុង ១ ហិកតា និងរួមផ្សំជាមួយជីគីមីដូចមានក្នុងតារាងទី ១។ សម្រាប់ពេលវេលានៃការបាចជីបំប៉ន គឺត្រូវធ្វើឡើងនៅរយៈពេល ៤៥ ថ្ងៃ ក្រោយពង្រោះ ឬ ៥០ ថ្ងៃ ក្រោយសាបសំណាប។



តារាងទី១៖ កម្រិតជីណែនាំតាមប្រភេទដី

| ក្រុមដី | ស្រូវស្រាលមិនប្រកាន់រដូវ (ស្រូវប្រាំង និងស្រូវវស្សា) | | | |
|---|---|---|---|---|
| | បាចទ្រាប់បាតមុនស្ទូង ឬព្រោះ (គ.ក្រ/ហាត) | | | បំប៉ន (គ.ក្រ/ហាត) |
| | អ៊ុយរ៉េ ៤៦-០-០ | ដេ អា ប៉េ ១៨-៤៦-០ | ប៉ូតាស្យូ ០-០-៦០ | អ៊ុយរ៉េ ៤៦-០-០ |
| ដីព្រៃខ្មែរ | ២០ | ២៥ | ៥០ | ២៥ |
| ដីប្រទះឡាង | ២៥ | ៥០ | ៥០ | ៥០ |
| ដីបាកាន ឬអូររាំង | ៥០ | ៦០ | ៥០ | ៨០ |
| ដីទួលសំរោង | ៥០ | ៥០ | ០ | ១០០ |
| ដីគោកត្រប់ | ៥០ | ៧៥ | ៥០ | ៧៥ |
| ដីកំពង់សៀម | ៥០ | ០ | ០ | ៥០ |
| ដីកៀនស្វាយ | ៦០ | ០ | ០ | ៦០ |
| ដីក្រគរ | ១០០ | ៥០ | ០ | ១០០ |
| ដីក្បាលពោធិ | ៨៥ | ០ | ០ | ៨៥ |

## ការប្រមូលផល

- ត្រូវប្រមូលផលស្រូវនៅពេលគ្រាប់ទុំល្អ គឺនៅពេលដែលកួរស្រូវមានគ្រាប់ចាប់ពីពាក់កណ្ដាលកួរឡើងទៅ មានពណ៌លឿងទុំចាស់ និងគ្រាប់ពេញពាក់កណ្ដាលកួរចុះក្រោម មានពណ៌លឿងទុំស្រាល ហើយគ្រាប់ស្អកវិញមានពណ៌ស្លាបសេកចាស់។
- គេអាចហាលសម្ងួតស្រូវនៅលើកន្ទេល សំណាញ់មុង តង់កៅស៊ូ និងលានស៊ីម៉ង់ត៍ គឺមិនបណ្ដាលឲ្យគុណភាពគ្រាប់ស្រូវ ឬគ្រាប់ស្រូវពូជខុសគ្នាឡើយ។ កម្រាស់គ្រាប់ស្រូវដែលសមស្របសម្រាប់ការហាលសម្ងួត គឺ ២-៣ ស.ម ដែលកម្រាស់គ្រាប់ និងសភាពពន្លឺថ្ងៃគឺជាកត្តាចម្បងក្នុងការកំណត់រយៈពេលហាល និងគុណភាពគ្រាប់ស្រូវ៖
  - ថ្ងៃស្រឡះល្អ ហាលតែ ១ ថ្ងៃ ប៉ុណ្ណោះ ដោយកន្លះម៉ោងរឹម្ដង។
  - ថ្ងៃស្រឡះបង្គួរ ហាលសម្ងួតរយៈពេល ២ ថ្ងៃ ដោយមួយម៉ោងរឹម្ដង។
  - ថ្ងៃមិនស្រឡះ គេត្រូវហាលរហូតដល់ ៣ ថ្ងៃ ដោយ ២ ម៉ោង រឹម្ដង។





- គ្រាប់ពូជត្រូវច្រកទុកនៅក្នុងថង់ប្លាស្ទិកចងឲ្យជិត រួចដាក់ក្នុងបាវមួយជាន់ទៀត ហើយទុកដាច់ដោយឡែកពីគ្រាប់ស្រូវចំណី នៅកន្លែងដែលស្ងួតល្អ និងគ្មានការបំផ្លាញពីសត្វកណ្ដុរ មាន់ ទាជាដើម។ ត្រូវសរសេរឈ្មោះពូជ និងថ្ងៃខែច្រូតកាត់ ដាក់នៅលើបាវឲ្យបានត្រឹមត្រូវល្អ។
- ផលស្រូវដែលប្រមូលបាន ត្រូវទុកដាក់ក្នុងជង្រុកឲ្យបានល្អ ដោយការពារកុំឲ្យសត្វកណ្ដុរ មាន់ ទាស៊ី និងមិនឲ្យទទឹក។

សម្រាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យរុក្ខជម្រើសវិទ្យា មជ្ឈមណ្ឌលបណ្ដុះបណ្ដាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្ដោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ ភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ

ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ គេហទំព័រ: www.cardi.org.kh

ទូរអក្ខរ: ssophany@cardi.org.kh trin@cardi.org.kh hunyadana@cardi.org.kh